# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

**លេខៈ**...០១...សសរ...

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារពិនិត្យ ផ្តល់មតិជូនគ្រឿងឥស្សរិយយស
## និង ការអនុញ្ញាតអោយស្ពាក់នៅដល់ធុរជនបរទេស

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរ និង ការងារចាំបាច់

## ស ម្រ េ ច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីពិនិត្យ ផ្តល់មតិជូន គ្រឿងឥស្សរិយយស និង ការអនុញ្ញាតអោយស្ពាក់នៅដល់ធុរជនបរទេស ដូចមានរាយនាមខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **ឈាអ៊ី** | **តាន់** | អគ្គលេខាធិការរាជរដ្ឋាភិបាល | ប្រធាន |
| ២-ឯកឧត្តម | **ប៊ុន** | **សំបូរ** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម | **ឡុង** | **វិសាលោ** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤-ឯកឧត្តម | **គឹម** | **ស៊ីថន** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥-ឯកឧត្តម | **យូ** | **ស៊ុនឡុង** | តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៦-ឯកឧត្តម | **ស៊ុយ** | **ម៉ុងលាង** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |

៤៥

៧-ឯកឧត្តម **ឱុយ ឆៅ** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៨-លោក **ស៊ឹម អៀង** និងលោក **កែវ សាវុធ** តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៩-លោក **លឹម សំកុល** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ សមាជិក

១០-លោក **ឆៀង ម៉ៅ** ប្រធាននាយកដ្ឋានឥស្សរិយយស លេខាអចិន្ត្រៃយ៍

**ប្រការ ២ :** ក្រុមការងារនេះមានការកិច្ច :

- ស្រាវជ្រាវរកឯកសារនានា ពាក់ព័ន្ធទៅ នឹង ការផ្តល់គ្រឿងឥស្សរិយយស និង ការស្លាក់នៅរបស់ធុរជនបរទេស ជាពិសេសច្បាប់របស់ប្រទេសជឿនលឿនមួយចំនួន ដែលគេបានអនុវត្តការងារនេះរួចហើយ ។
- រៀបចំលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល សំរាប់កំណត់លើបញ្ហាខាងលើ ។
- រៀបចំលើកសំណើ សុំគ្រឿងឥស្សរិយយស ជូនសម្តេចនាយករដ្ឋមន្ត្រីដើម្បីពិនិត្យ និង សំរេច ។

**ប្រការ ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង - ស្ថាប័ន ដែលពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ដូចក្នុងប្រការ ៣
- ឯកសារ - កាលប្បវត្តិ